ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ១៨៥ មស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសនិស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងពាណិជ្ជកម្ម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០២១

**យោង ៖**
- លិខិតលេខ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីផែនការក្របខ័ណ្ឌឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ១៩២៧ មស.ក្រខ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងការអនុវត្តកម្មសិក្សា សម្រាប់ផែនការក្របខ័ណ្ឌឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ៣៧៥៩ មស.ក្រខ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីផែនការក្របខ័ណ្ឌឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ៤០៩៣ មស.ក្រខ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋសម្រាប់ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ
- សេចក្តីណែនាំលេខ៤១៥៧ មស.សណន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការប្រឡង និងភារកិច្ចរបស់គណៈកម្មការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលសម្រាប់ក្របខ័ណ្ឌរដ្ឋឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ៣៩១៧ មស.ក្រខ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- សេចក្តីជូនដំណឹងលេខ៩៧៨ មស.សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០របស់ក្រសួងមុខងារសាធារណៈ។

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនដំណឹងដល់និស្សិត និងមន្ត្រីរាជការស៊ីវិលទាំងអស់ ឱ្យបានជ្រាបថា ក្រសួងមុខងារសាធារណៈ សម្រេចបន្តឱ្យមានការទទួលពាក្យសុំសិទ្ធិប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល ចំនួន ២២២កន្លែង ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន ទាំង០៦ សម្រាប់ឆ្នាំ២០២១ ដូចខាងក្រោម៖

**១-ក្រសួងមុខងារសាធារណៈ** ចំនួន ០៨កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។

**២-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច** ចំនួន ០៥កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ចំនួន ១៣៣កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ។ បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬ សញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| **ល.រ** | **អង្គភាព** | **ចំនួនក្របខ័ណ្ឌ** | | | **ជំនាញដែលជ្រើសរើស** |
|---|---|---|---|---|---|
| | | **ក** | **ខ** | **សរុប** | |
| **ក. ថ្នាក់កណ្តាល** | | | | | |
| ១ | នាយកដ្ឋានកិច្ចការរដ្ឋបាល | ២ | ០ | ២ | រដ្ឋបាលសាធារណៈ គ្រប់គ្រង នីតិសាស្ត្រ ភាសាចិន ព័ត៌មានវិទ្យា សរសេរសារព័ត៌មាន គណនេយ្យ-ហិរញ្ញវត្ថុ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |
| ២ | នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | ២ | ០ | ២ | គណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ គ្រប់គ្រង នីតិសាស្ត្រ ព័ត៌មានវិទ្យា |
| ៣ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ២ | ០ | ២ | សវនកម្ម-អធិការកិច្ច គណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ នីតិសាស្ត្រ ព័ត៌មានវិទ្យា |
| ៤ | នាយកដ្ឋានផែនការនិងស្ថិតិ | ១ | ១ | ២ | ផែនការ ស្ថិតិ សេដ្ឋកិច្ចនិងអភិវឌ្ឍន៍ជនបទ គ្រប់គ្រង នីតិសាស្ត្រ ព័ត៌មានវិទ្យា |
| ៥ | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | ២ | ០ | ២ | ទំនាក់ទំនងអន្តរជាតិ ភាសាអង់គ្លេស នីតិសាស្ត្រ ព័ត៌មានវិទ្យា គ្រប់គ្រង ភាសាចិន សរសេរសារព័ត៌មាន |
| ៦ | នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | ៣ | ០ | ៣ | គណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ គ្រប់គ្រង នីតិសាស្ត្រ ព័ត៌មានវិទ្យា ភាសាអង់គ្លេស |
| ៧ | អគ្គាធិការដ្ឋាន | ២ | ០ | ២ | អធិការកិច្ច គ្រប់គ្រង នីតិសាស្ត្រ ព័ត៌មានវិទ្យា រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |
| ៨ | នាយកដ្ឋាននីតិកម្មកសិកម្ម | ២ | ០ | ២ | នីតិសាស្ត្រ វិទ្យាសាស្ត្រកសិកម្ម ព័ត៌មានវិទ្យា គីមីវិទ្យា គ្រប់គ្រង |
| ៩ | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | ៤ | ០ | ៤ | វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ នីតិសាស្ត្រ គីមីចំណីអាហារ គណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ |
| ១០ | នាយកដ្ឋានកសិឧស្សាហកម្ម | ២ | ០ | ២ | កសិ-ឧស្សាហកម្ម គីមីចំណីអាហារ គ្រប់គ្រង នីតិសាស្ត្រ គណនេយ្យ-ហិរញ្ញវត្ថុ |
| ១១ | រដ្ឋបាលជលផល | ៥ | ០ | ៥ | វិទ្យាសាស្ត្រជលផល បរិស្ថាន រដ្ឋបាលសាធារណៈ នីតិសាស្ត្រ ព័ត៌មានវិទ្យា គីមីវិទ្យា |
| ១២ | រដ្ឋបាលព្រៃឈើ | ៣ | ០ | ៣ | វិទ្យាសាស្ត្រព្រៃឈើ បរិស្ថាន គណនេយ្យ-ហិរញ្ញវត្ថុ គ្រប់គ្រង នីតិសាស្ត្រ ព័ត៌មានវិទ្យា ជីវៈគីមី រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |
| ១៣ | អគ្គនាយកដ្ឋានកសិកម្ម | ៦ | ០ | ៦ | ក្សេត្រសាស្ត្រ គីមីវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ នីតិសាស្ត្រ វិស្វកម្មកសិកម្ម គ្រប់គ្រង គណនេយ្យ-ហិរញ្ញវត្ថុ |
| ១៤ | អគ្គនាយកដ្ឋានកៅស៊ូ | ៣ | ០ | ៣ | ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រកៅស៊ូ គណនេយ្យ-ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា គ្រប់គ្រង |
| ១៥ | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ៤ | ០ | ៤ | ក្សេត្រសាស្ត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ គណនេយ្យ-ហិរញ្ញវត្ថុ នីតិសាស្ត្រ ព័ត៌មានវិទ្យា គ្រប់គ្រង គីមីវិទ្យា វិស្វកម្មកសិកម្ម |
| ១៦ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤ | ០ | ៤ | ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រកៅស៊ូ គណនេយ្យ-ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា គ្រប់គ្រង គីមីវិទ្យា នីតិសាស្ត្រ |

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | | ជំនាញដែលជ្រើសរើស |
| --- | --- | --- | --- | --- | --- |
| | | ក | ខ | សរុប | |
| ១៧ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៣ | ០ | ៣ | ក្សេត្រសាស្ត្រ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ កសិ-ឧស្សាហកម្ម ជលផល ព្រៃឈើ គណនេយ្យហិរញ្ញវត្ថុ នីតិសាស្ត្រ ព័ត៌មានវិទ្យា |
| ១៨ | វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | ២ | ០ | ២ | ក្សេត្រសាស្ត្រ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ នីតិសាស្ត្រ ព័ត៌មានវិទ្យា គីមីចំណីអាហារ |
| ១៩ | វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ នីតិសាស្ត្រ គីមីចំណីអាហារ |
| ២០ | មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម | ២ | ០ | ២ | ព័ត៌មានវិទ្យា គណនេយ្យ-ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ គ្រប់គ្រង នីតិសាស្ត្រ ភាសាអង់គ្លេស |
| ២១ | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥ | ០ | ៥ | សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ គណនេយ្យ-ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា គ្រប់គ្រង ភាសាអង់គ្លេស |
| **ខ. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ រាជធានី ខេត្ត** | | | | | |
| ១ | រាជធានីភ្នំពេញ | ១ | ០ | ១ | វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម គណនេយ្យហិរញ្ញវត្ថុ |
| ២ | ខេត្តកណ្ដាល | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម ព័ត៌មានវិទ្យា |
| ៣ | ខេត្តតាកែវ | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម រដ្ឋបាលសាធារណៈ |
| ៤ | ខេត្តព្រៃវែង | ៤ | ១ | ៥ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម ព័ត៌មានវិទ្យា |
| ៥ | ខេត្តស្វាយរៀង | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គ្រប់គ្រង គណនេយ្យ-ហិរញ្ញវត្ថុ |
| ៦ | ខេត្តកំពត | ៣ | ១ | ៤ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម ព័ត៌មានវិទ្យា |
| ៧ | ខេត្តកំពង់ស្ពឺ | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |
| ៨ | ខេត្តកោះកុង | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | | ជំនាញដែលជ្រើសរើស |
|---|---|---|---|---|---|
| | | ក | ខ | សរុប | |
| ៩ | ខេត្តកំពង់ចាម | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គណនេយ្យ-ហិរញ្ញវត្ថុ គ្រប់គ្រង |
| ១០ | ខេត្តត្បូងឃ្មុំ | ៣ | ១ | ៤ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី |
| ១១ | ខេត្តកំពង់ធំ | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម រដ្ឋបាលសាធារណៈ |
| ១២ | ខេត្តព្រះវិហារ | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម |
| ១៣ | ខេត្តសៀមរាប | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គណនេយ្យ-ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| ១៤ | ខេត្តកំពង់ឆ្នាំង | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម |
| ១៥ | ខេត្តពោធិ៍សាត់ | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គ្រប់គ្រង |
| ១៦ | ខេត្តបាត់ដំបង | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម ព័ត៌មានវិទ្យា |
| ១៧ | ខេត្តបន្ទាយមានជ័យ | ៣ | ០ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គណនេយ្យ-ហិរញ្ញវត្ថុ គ្រប់គ្រង |
| ១៨ | ខេត្តឧត្តរមានជ័យ | ៣ | ០ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម |
| ១៩ | ខេត្តក្រចេះ | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម រដ្ឋបាលសាធារណៈ |
| ២០ | ខេត្តស្ទឹងត្រែង | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម រដ្ឋបាលសាធារណៈ |
| ២១ | ខេត្តរតនគិរី | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម វិស្វកម្មកសិកម្ម គណនេយ្យ-ហិរញ្ញវត្ថុ |
| ២២ | ខេត្តមណ្ឌលគិរី | ២ | ១ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម គណនេយ្យ-ហិរញ្ញវត្ថុ |
| ២៣ | ខេត្តព្រះសីហនុ | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម ព័ត៌មានវិទ្យា |

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | | ជំនាញដែលជ្រើសរើស |
|---|---|---|---|---|---|
| | | ក | ខ | សរុប | |
| ២៤ | ខេត្តកែប | ៣ | ០ | ៣ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម ព័ត៌មានវិទ្យា |
| ២៥ | ខេត្តប៉ៃលិន | ២ | ០ | ២ | ក្សេត្រសាស្ត្រ ជលផល ព្រៃឈើ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ កសិ-ឧស្សាហកម្ម គណនេយ្យ-ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា |
| សរុប | | ១១៧ | ១៦ | ១៣៣ | |

**៤-ក្រសួងពាណិជ្ជកម្ម** ចំនួន ៣៦កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។ បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬ សញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | | ជំនាញជ្រើសរើស |
|---|---|---|---|---|---|
| | | ក | ខ | សរុប | |
| **ក. ទីស្តីការក្រសួង** | | ១៧ | ២ | ១៩ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| **ខ. មន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត** | | | | | |
| ១ | រាជធានីភ្នំពេញ | ៣ | ០ | ៣ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ២ | ខេត្តពោធិ៍សាត់ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៣ | ខេត្តកំពង់ធំ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៤ | ខេត្តកំពង់ឆ្នាំង | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៥ | ខេត្តសៀមរាប | ២ | ០ | ២ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៦ | ខេត្តកំពង់ស្ពឺ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៧ | ខេត្តព្រះវិហារ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ចសហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | | ជំនាញជ្រើសរើស |
|---|---|---|---|---|---|
| | | ក | ខ | សរុប | |
| ៨ | ខេត្តឧត្តរមានជ័យ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ៩ | ខេត្តមណ្ឌលគិរី | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ១០ | ខេត្តរតនគិរី | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ១១ | ខេត្តកំពង់ចាម | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ១២ | ខេត្តកំពត | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ១៣ | ខេត្តកែប | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេស រដ្ឋបាលសាធារណៈ |
| ១៤ | ខេត្តត្បូងឃ្មុំ | ១ | ០ | ១ | គ្រប់គ្រងទូទៅ គ្រប់គ្រង សេដ្ឋកិច្ច ពាណិជ្ជកម្ម ធុរៈកិច្ច សហគ្រាស គណនេយ្យ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ ភាសាអង់គ្លេសរដ្ឋបាលសាធារណៈ |
| សរុប | | ៣៤ | ២ | ៣៦ | |

**៥-ក្រសួងធនធានទឹកនិងឧតុនិយម** ចំនួន ២៨កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល លើមុខជំនាញ នីតិសាស្ត្រ, ព័ត៌មានវិទ្យា វិស្វករធនធានទឹក/សំណង់ធារាសាស្ត្រ, សំណង់ស៊ីវិល, គណនេយ្យ-ហិរញ្ញវត្ថុ សេដ្ឋកិច្ចអភិវឌ្ឍន៍ជនបទ គ្រប់គ្រង និងភាសាបរទេស ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខ័ណ្ឌ |
|---|---|---|---|
| ក. ទីស្តីការក្រសួង | | | |
| ១ | នាយកដ្ឋានហិរញ្ញវត្ថុ | ២ | ក |
| ២ | នាយកដ្ឋានធារាសាស្ត្រកសិកម្ម | ៣ | ក |
| ៣ | នាយកដ្ឋានវិស្វកម្ម | ៣ | ក |
| ៤ | នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក | ១ | ក |
| ខ. មន្ទីរធនធានទឹកនិងឧតុនិយម រាជធានី ខេត្ត | | | |
| ១ | រាជធានីភ្នំពេញ | ១ | ក |

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខ័ណ្ឌ |
|---|---|---|---|
| ២ | ខេត្តកណ្ដាល | ១ | ក |
| ៣ | ខេត្តព្រះសីហនុ | ២ | ក |
| ៤ | ខេត្តស្វាយរៀង | ១ | ក |
| ៥ | ខេត្តកំពង់ធំ | ១ | ក |
| ៦ | ខេត្តស្ទឹងត្រែង | ១ | ក |
| ៧ | ខេត្តកោះកុង | ១ | ក |
| ៨ | ខេត្តសៀមរាប | ១ | ក |
| ៩ | ខេត្តព្រៃវែង | ១ | ក |
| ១០ | ខេត្តកំពង់ឆ្នាំង | ១ | ក |
| ១១ | ខេត្តកំពង់ស្ពឺ | ២ | ក |
| ១២ | ខេត្តបាត់ដំបង | ២ | ក |
| ១៣ | ខេត្តបន្ទាយមានជ័យ | ១ | ក |
| ១៤ | ខេត្តកែប | ២ | ក |
| ១៥ | ខេត្តពោធិ៍សាត់ | ១ | ក |
| សរុប | | ២៨ | |

**៦-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** ចំនួន ១២កន្លែង សម្រាប់បេក្ខជនប្រឡងក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូលលើមុខជំនាញ អក្សរសាស្ត្រអង់គ្លេស ព័ត៌មានវិទ្យា, សេដ្ឋកិច្ច, ធនាគារ និងហិរញ្ញវត្ថុ ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខ័ណ្ឌ |
|---|---|---|---|
| ១ | អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | ០១ | ក |
| ២ | នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន | ០២ | ក |
| ៣ | នាយកដ្ឋានសេវាកម្មអាកាសចរណ៍រាជធានីភ្នំពេញ | ០១ | ក |
| ៤ | ការិយាល័យឧតុនិយម (ខេត្តសៀមរាប) | ០១ | ក |
| ៥ | ការិយាល័យឧតុនិយម (ខេត្តព្រះសីហនុ) | ០១ | ក |
| ៦ | នាយកដ្ឋានលទ្ធភាពហោះហើរ | ០៣ | ក |
| ៧ | នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស | ០១ | ក |
| ៨ | នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស | ០២ | ក |
| សរុប | | ១២ | |

**ក-លក្ខខណ្ឌជ្រើសរើស**

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនត្រូវមានអាយុ ចាប់ពី១៨ឆ្នាំឡើងទៅ

៣. លក្ខខណ្ឌអាយុត្រូវបានកំណត់ក្នុងផែនការឆ្នាំ ដូចមានខាងក្រោម៖

- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររងឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ

៤. ចំពោះបេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ

បេក្ខជនជាមន្ត្រីរាជការត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង ស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ នៅតាមក្រសួង ស្ថាប័ន ឬអង្គភាពណាមួយ ហើយត្រូវបានរៀបចំផ្ទេរក្របខ័ណ្ឌទៅកន្លែងថ្មី បេក្ខជនជាមន្ត្រីរាជការត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ។

៥. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

៦. ចំពោះបេក្ខជនជានារី ជនពិការ និងអ្នករស់នៅតំបន់ដាច់ស្រយាល ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត

៧. សញ្ញាបត្រ ឬ លិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិតជំនាញ ត្រូវបានដាក់វិធានការដូចខាងក្រោម៖

- ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬ លិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះប្រឡងជាប់ក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នណាមួយក៏ដោយ
- ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេស ឬសញ្ញាបត្រជាភាសាបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ខ-សំណុំលិខិតចុះឈ្មោះសុំសិទ្ធិប្រឡង៖**

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤ x ៦) | ចំនួន ០១ច្បាប់ |
| ៣. សលាកប័ត្រឯកត្តជន | ចំនួន ០១ច្បាប់ |
| ៤. បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |
| ៥. កិច្ចសន្យាការងារ (ផ្អែកតាមលក្ខខណ្ឌតម្រូវរបស់សាមីក្រសួង ស្ថាប័ន) | ចំនួន ០១ច្បាប់ |
| ៦. សេចក្តីថតចម្លងសញ្ញាបត្រជំនាញ (ត្រូវមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ) | ចំនួន ០១ច្បាប់ |
| ៧. សេចក្តីថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| ៩. លិខិតអនុញ្ញាតរបស់ប្រធានក្រសួង ស្ថាប័ន (សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| ១០. ច្បាប់ដើមព្រឹត្តិបត្រពិន្ទុបញ្ចប់ឆ្នាំសិក្សា ភ្ជាប់មកជាមួយ (សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ) | ចំនួន ០១ច្បាប់ |

**គ-វិញ្ញាសាប្រឡង**

**១.ក្រសួងពាណិជ្ជកម្ម**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធវិស័យពាណិជ្ជកម្ម រយៈពេល ០១ម៉ោង ៖ ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័ររយៈពេល ០១ម៉ោង ៖ ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ **ក** និង **ខ**

**២. ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

- ម៉ោងទី១៖ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ រយៈពេល ០១ម៉ោង ៖ ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ **ក** និង **ខ**
- ម៉ោងទី២៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័ររយៈពេល ០១ម៉ោង ៖ ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ **ក** និង **ខ**

**ឃ-កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យ៖**

១. កាលបរិច្ឆេទទទួលពាក្យ ចាប់ពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ពេលព្រឹកចាប់ពីម៉ោង ០៨៖០០នាទី ដល់ម៉ោង ១១៖៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤៖០០នាទី ដល់ម៉ោង ១៧៖០០នាទី

២. កាលបរិច្ឆេទឈប់ទទួលពាក្យនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៧៖០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។

៣. ទីកន្លែងទទួលពាក្យនិងដាក់ពាក្យសុំសិទ្ធិប្រឡង៖

- បេក្ខជនដែលដាក់ពាក្យសុំសិទ្ធិប្រឡងនៅក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវមកទទួលពាក្យ និងដាក់ពាក្យសុំសិទ្ធិប្រឡង នៅនាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ នៃក្រសួងមុខងារសាធារណៈ **(អគារបែរមុខទៅលិច ជាន់ផ្ទាល់ដី បន្ទប់ A05)**។

- បេក្ខជនដែលដាក់ពាក្យសុំសិទ្ធិប្រឡងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងតាមបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវមកទទួលពាក្យ និងដាក់ពាក្យសុំសិទ្ធិប្រឡងនៅនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

**បញ្ជាក់៖ បេក្ខជនទាំងអស់ត្រូវមកដាក់ពាក្យសុំសិទ្ធិប្រឡងដោយខ្លួនឯងផ្ទាល់។**

**ង-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង**

គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹងអំពីកាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡងនៅពេលក្រោយ។ សូមបេក្ខជនទាំងអស់តាមដានព័ត៌មាននៅគេហទំព័ររបស់ក្រសួងមុខងារសាធារណៈតាមរយៈអាសយដ្ឋាន( www.mcs.gov.kh) និងតាមបណ្តាញគេហទំព័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតាមបណ្តាញសង្គមហ្វេសប៊ុករបស់ក្រសួងមុខងារសាធារណៈ ( http://facebook.com/CivilServiceCambodia/ )។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង តំណាងក្រសួង ស្ថាប័នដូចខាងក្រោម៖

១. ក្រសួងមុខងារសាធារណៈ

ទូរស័ព្ទលេខ៖ ០១២ ៣៥១១១៤ / ០១៧ ៦៥១៣២៣ / ០១២ ៣៣១០០៧ / ០៨៩ ៩៧៨៦៧៨

០១២ ៣០៥៥៣០ / ០១៧ ៩០០១២៩ / ០១២ ៧៩១៨៩១ / ០៧៨ ៧៧៧៩០៧

២.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទូរស័ព្ទលេខ៖ ០១២ ៧២៧៦៦៤ / ០១២ ៩១២៧២៦ / ០១២ ២៦០៨០១ / ០១២ ៥៣៧៣៧៣

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមរួសរាន់មកទទួលពាក្យសុំសិទ្ធិប្រឡងដើម្បីបំពេញសំណុំបែបបទប្រឡងប្រជែងជ្រើសរើសតាមក្រសួង ស្ថាប័ន ណាមួយដែលខ្លួនមានបំណងចង់ចូលបម្រើការងារ ដូចបានរៀបរាប់ខាងលើនេះ។

បញ្ជាក់៖ -បេក្ខជនអាចដាក់ពាក្យសុំសិទ្ធិប្រឡងបានតែមួយក្រសួង ស្ថាប័ន តែប៉ុណ្ណោះ។

-ចំពោះបេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធិប្រឡង កាលពីឆ្នាំ២០២០ រួចមកហើយ មិនតម្រូវឱ្យដាក់ពាក្យសុំសិទ្ធិប្រឡងឡើងវិញទេ។

កំណត់សម្គាល់៖ គណៈកម្មការរៀបចំការប្រឡង សូមរក្សាសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់។

※ ព័ត៌មានលម្អិត សូមធ្វើការទាក់ទងមកក្រសួងមុខងារសាធារណៈ ដែលមានទីតាំងស្ថិតនៅ ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ( ទល់មុខវត្តអង្គតាមិញ )។

ថ្ងៃ ពុធ ៧ កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អែម ម៉ុនផុល**

**ចម្លងជូន៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

" ដើម្បីសហការអនុវត្ត និងផ្សព្វផ្សាយ "

-ឯកសារ កាលប្បវត្តិ